## ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
## អភិបូជាបុណ្យទេវទូតជូនដំណឹងព្រះនាងម៉ារី
## អរិយក្សត្រ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០
## យើងផ្ញើអ្វីៗទាំងអស់ទៅព្រះជាម្ចាស់តាមរយៈព្រះនាងម៉ារី

**អត្ថបទទី១៖ អេសាយ ៧,១០-១៤.៨,១០**

«ព្រះករុណាត្រូវទូលសុំព្រះអម្ចាស់ ជាព្រះរបស់ព្រះករុណា សម្ដែងនូវទីសម្គាល់មួយ ទោះបីនៅលើភ្នំដ៏ខ្ពស់ក្ដី ឬក្នុងទីដ៏ជ្រៅក្ដី ដើម្បីបញ្ជាក់ថា ព្រះអង្គពិតជាគង់នៅជាមួយព្រះករុណា»។ ព្រះបាទអខាសមានរាជឱង្ការតបមកវិញថា៖ «យើងនឹងមិនទូលសូមអ្វីជាដាច់ខាត យើងនឹងមិនព្រមល្បងលព្រះអម្ចាស់ឡើយ!»។ អស ៧,១១-១២

**អត្ថបទទី២៖ ហេប្រឺ ១០,៤-១០**

ទូលបង្គំពោលថា: បពិត្រព្រះជាម្ចាស់ ឥឡូវនេះ ទូលបង្គំសូមមក ធ្វើតាមព្រះហឫទ័យរបស់ព្រះអង្គ ស្របតាមសេចក្ដីដែលមានចែងទុកពីទូលបង្គំ នៅក្នុងគម្ពីរ»។ ហប ១០,៧

**ដំណឹងល្អ៖ លូកា ១,២៦-៣៨**

ទេវទូតចូលទៅក្នុងផ្ទះនាងម៉ារី ហើយពោលទៅកាន់នាងថា៖ «ចូរមានអំណរសប្បាយឡើង! ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ ព្រះអង្គគង់ជាមួយនាង»។លក ១,២៨

បងប្អូនជាទីស្រឡាញ់!

បងប្អូនកំពុងជួបជុំគ្នាអធិដ្ឋានតាមផ្ទះ ថ្ងៃនេះខ្ញុំមកដល់កន្លែងព្រះនាងម៉ារីនៃទន្លេមេគង្គ អរិយក្សត្រ ព្រះវិហារក្សត្រីនៃសន្តិភាព។ ថ្ងៃនេះ យើងគោរពបុណ្យព្រះនាងម៉ារីទទួលដំណឹងពីទេវទូតកាព្រីអែល ជាឱកាសមួយសម្រាប់យើងជាគ្រីស្ដបរិស័ទ ដើម្បីអធិដ្ឋាននៅក្នុងរបៀបមួយដែលណែនាំឲ្យយើងភ្ជាប់ជាមួយព្រះយេស៊ូ។ ខ្ញុំបានអញ្ជើញបងប្អូនទាំងអស់ ឲ្យអុជទៀននៅតាមផ្ទះដើម្បីនឹកឃើញដល់ព្រះយេស៊ូដែលជាពន្លឺ យាងមកបំភ្លឺពិភពលោករបស់យើងកំពុងភ្ជាប់នឹងភាពងងឹតសព្វថ្ងៃ។

ជារៀងរាល់ឆ្នាំ នៅក្នុងរដូវ៤០ថ្ងៃព្រះសហគមន៍ដូចជាបានប្រគល់ឱកាសមួយយ៉ាងពិសេស ដើម្បីឲ្យយើងទទួលស្វាគមន៍ព្រះយេស៊ូដែលកើតជាមនុស្ស ព្រះយេស៊ូដែលសោយទិវង្គត និងព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។ ឆ្នាំនេះ យើងមានរដូវអប់រំពិសេសដែលណែនាំឲ្យយើងចូលនៅក្នុងទុក្ខលំបាកនៃពិភពលោកទាំងមូល យើងចូលនៅក្នុងវាលរហោស្ថាន យើងចូលនៅក្នុងការភ័យខ្លាច។ យើងដឹងថា សេចក្ដីស្លាប់ដូចជាបានដើរជុំវិញយើងទូទាំងពិភពលោក ប៉ុន្តែយប់នេះព្រះនាងម៉ារីបានទទួលដំណឹងមួយយ៉ាងពិសេសបំផុត។ ដំណឹងនេះ បានណែនាំឲ្យពិភពលោកប្រែប្រួលអស់ហើយ នៅពេលហ្នឹងព្រះនាងម៉ារីទៅជាមាតារបស់ព្រះជា

ម្ចាស់ "**កុំខ្លាចអីម៉ារីអើយ ត្បិតព្រះជាម្ចាស់គាប់ព្រះហឫទ័យនឹងនាងហើយ នាងនឹងមានគភ៌ សម្រាលបានបុត្រមួយដែលនាងត្រូវថ្វាយព្រះនាមថាយេស៊ូ បុត្រនោះនឹងមានឋានៈដ៏ប្រសើរឧត្ដម ហើយគេនឹងថ្វាយព្រះនាមថាព្រះបុត្រានៃព្រះដ៏ខ្ពង់ខ្ពស់បំផុត**"។ នៅពេលនេះ ឥតមានអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើត និងដោយសារនៅក្នុងសេរីភាពរបស់ព្រះនាងម៉ារី ដូចជានៅក្នុងសេចក្ដីស្រឡាញ់ដែលគ្មានព្រំដែនចំពោះព្រះជាម្ចាស់ ព្រះនាងម៉ារីបានឆ្លើយថា "**នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់ សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ**"។ ដោយសារចម្លើយរបស់ព្រះនាងម៉ារីពិភពលោកទាំងមូលបានប្រែប្រួលអស់ហើយ ព្រះជាម្ចាស់បានចាប់កំណើតជាមនុស្ស ព្រះជាម្ចាស់ចូលនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្សលោក ដោយបានចាត់ព្រះបុត្រាដ៏ជាទីស្រឡាញ់របស់ព្រះអង្គយាងមកដើម្បីរំដោះពិភពលោកពីអំពើបាប និងដើម្បីណែនាំឲ្យពិភពលោកទទួលជីវិតអស់កល្បជានិច្ច។

យប់នេះ នៅក្បែរព្រះនាងម៉ារីដែលជាមាតារបស់ព្រះជាម្ចាស់ ដែលជាមាតារបស់យើង យើងថ្វាយទុក្ខលំបាករបស់យើង និងជាពិសេសទុក្ខលំបាករបស់ពិភពលោក។

យប់នេះ មានជាង២០០០លាននាក់ដែលជាប់នៅក្នុងផ្ទះគ្មានសិទ្ធិចេញធ្វើដំណើរ ជួនកាលមានមនុស្សមួយចំនួនបានចូលនៅក្នុងជីវិតឯកោ ដែលកំពុងភ័យខ្លាចពីមួយថ្ងៃទៅមួយថ្ងៃសម្រាប់សុខភាពផ្ទាល់ខ្លួន និងសម្រាប់សុខភាពបងប្អូនឯទៀតៗដែរ។ ទុក្ខលំបាកដែលយើងថ្វាយទៅព្រះជាម្ចាស់ គឺមានមនុស្សរាប់ពាន់នាក់ដែលបានទទួលមរណភាព មានមនុស្សមួយចំនួនបាននៅឆ្ងាយពីក្រុមគ្រួសារក្នុងពេលវេលាចុងក្រោយលើផែនដីនេះ។

យប់នេះ យើងថ្វាយទៅព្រះនាងម៉ារីមានបងប្អូនរាប់ម៉ឺននាក់ដែលកំពុងកើតជំងឺកូវីដ១៩ និងកំពុងប្រឆាំងព្រមទាំងខិតខំព្យាបាលអស់ពីសមត្ថភាព។

យប់នេះ យើងថ្វាយទៅព្រះនាងម៉ារីបងប្អូនដែលជាក្រុមគ្រូពេទ្យបានជួយថែរក្សាអ្នកជំងឺតាមមន្ទីរពេទ្យនីមួយៗក្នុងពិភពលោកទាំងមូល ជួនកាលគ្រូពេទ្យមួយចំនួននិងបងប្អូនដែលធ្វើការនៅមន្ទីរពេទ្យ បានធ្វើការអស់ពីកម្លាំងកាយកម្លាំងចិត្តរហូតដល់ទទួលមរណភាពដែរ។

យប់នេះ យើងផ្ញើទៅព្រះនាងម៉ារីបងប្អូនទាំងអស់ដែលបាត់បង់ការងារ ផ្អាកការរកស៊ីនៅក្នុងពិភពលោកទាំងមូល យើងមើលសេដ្ឋកិច្ចពិភពលោកបានធ្លាក់ចុះជិតស្មើសូន្យ។

យប់នេះ យើងថ្វាយទៅព្រះនាងម៉ារីប្រទេសដែលសព្វថ្ងៃនៅបន្តធ្វើសង្គ្រាម ប្រទេសដែលសព្វថ្ងៃខ្វះម្ហូបអាហារណែនាំឲ្យបងប្អូនគ្មានកម្លាំងកាយកម្លាំងចិត្តដើម្បីប្រឆាំងនឹងមេរោគថ្មីនេះ។

យប់នេះ សម្រាប់យើងដែលជាប្រជាជនកម្ពុជាយើងថ្វាយប្រទេសរបស់យើងទៅព្រះនាងម៉ារី ថ្វាយអ្នកជំងឺដែលកើនចំនួនពីមួយថ្ងៃទៅមួយថ្ងៃ ថ្វាយបងប្អូនកម្មករដែលកំពុងធ្វើដំណើរត្រលប់មកពីប្រទេសថៃ ដោយអស់ការងារធ្វើផង ដោយពិបាកចូលនៅតាមភូមិនានាព្រោះប្រជាជនភ័យខ្លាចឆ្លងកូវីដ១៩នេះ។

យប់នេះ យើងថ្វាយបងប្អូនទាំងអស់ដែលជាកម្មករកម្មការិនីដែលធ្វើការតាមរោងចក្រនៅក្នុងប្រទេសយើង បងប្អូនទាំងអស់ដែលកំពុងបាត់បង់ការងារ ដោយសារពីមួយថ្ងៃទៅមួយថ្ងៃបានបិទកន្លែងមួយចំនួនដោយគ្មានប្រាក់ខែ ដែលទៅផ្ទះដៃទទេ។

យប់នេះ យើងជាប្រជាជនកម្ពុជាយើងធ្វើការភ័យខ្លាចថ្វាយទៅព្រះនាងម៉ារី "**ឱព្រះនាងម៉ារីអើយ! ដែលជាមាតាដ៏ជាទីស្រឡាញ់របស់យើង ដែលជាសាវ័កមុនគេបង្អស់របស់ព្រះយេស៊ូ ដែលភ្ជាប់នឹងព្រះហប្ញទ័យរបស់ព្រះជាម្ចាស់នៅស្ថានបរមសុខ ឱព្រះនាងម៉ារីអើយ! សូមទទួលស្វាគមន៍បងប្អូនយើងទាំងអស់ដែលទទួលមរណភាពហើយ ដែលកំពុងទទួលមរណភាពនៅក្នុងភាពសម្ងាត់នៃការភ័យខ្លាច ឱព្រះនាងម៉ារីអើយ! ដែលជាមាតាដ៏ជាទីស្រឡាញ់របស់យើង សូមគង់នៅជាមួយយើងពីមួយនាទីទៅមួយនាទីពីមួយថ្ងៃទៅមួយថ្ងៃ នៅក្នុងគ្រប់កាលៈទេសៈនៃជីវិតរបស់យើង ដើម្បីជួយយើងឲ្យយើងស្វាគមន៍ព្រះហប្ញទ័យរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង ដូចព្រះនាងម៉ារីបានឆ្លើយទៅទេវទូតព្រះអង្គថា នាងខ្ញុំជាអ្នកបម្រើរបស់ព្រះអម្ចាស់សូមឲ្យបានសម្រេចតាមពាក្យរបស់លោកចុះ**"។

យប់នេះ យើងសម្លឹងមើលព្រះនាងម៉ារីដែលពោរពេញដោយព្រះហប្ញទ័យរបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីជាស្ត្រីដែលលើសពីស្ត្រីទាំងអស់ ដែលណែនាំឲ្យយើងចូលនៅក្នុងគម្រោងការពីដំបូងរបស់ព្រះជាម្ចាស់ ដែលបានបង្កើតបុរសនិងស្ត្រី ព្រះជាម្ចាស់ដែលបង្កើតមនុស្សយើងដើម្បីឲ្យបានពោរពេញដោយសុភមង្គល។

យប់នេះ យើងសម្លឹងមើលតាមរយៈព្រះនាងម៉ារីគម្រោងការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់មនុស្សលោក ដែលណែនាំឲ្យយើងដឹងថាយើងមានសេចក្ដីសង្ឃឹមទៅលើព្រះយេស៊ូដែលជាព្រះសង្គ្រោះយាងមកដើម្បីឲ្យយើងមានជីវិតអស់កល្បជានិច្ច។

យប់នេះ ជាពេលវេលាដើម្បីឲ្យយើងទាំងអស់ ទាំងនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្នុងពិភពលោក ឲ្យយើងភ្ញាក់ស្មារតីដើម្បីរកឃើញសេចក្តីស្រឡាញ់ថែមទៀត ដើម្បីរកឃើញកម្លាំងកាយកម្លាំងចិត្តថែមទៀត ដើម្បីចូលនៅក្នុងផ្លូវថ្មីដែលព្រះជាម្ចាស់កំពុងបើកឲ្យយើង។ យើងជាប់នៅក្នុងផ្ទះរបស់យើងក្តី យើងនៅមានសិទ្ធិធ្វើដំណើរក្តី បងប្អូនដែលទទួលមរណភាពក្តី ខ្ញុំគិតថានេះជាពេលវេលាដែលព្រះជាម្ចាស់ត្រាស់ហៅមនុស្សលោកទាំងមូល ដើម្បីរកឃើញតម្លៃនៃជីវិត អត្ថន័យនៃជីវិតរបស់យើង ឫសរបស់យើង សេចក្តីសង្ឃឹមរបស់យើង និងកម្លាំងក្លាហានដើម្បីប្រឆាំងមារសាតាំង សត្រូវដែលមិនអាចសម្លាប់យើងបានទេ។

យប់នេះ យើងត្រូវការនឹកឃើញជីវិតរបស់យើងជាជីវិតដ៏សក្ការៈបំផុត ដែលមានតម្លៃថ្លៃថ្នូរដ៏ខ្ពង់ខ្ពស់បំផុត ខ្ញុំគិតថាជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ដែលមនុស្សលោកកំពុងប្រយុទ្ធប្រឆាំងនឹងមេរោគមួយដោយយល់ថា អាទិភាពទីមួយគឺការពារថែរក្សាជីវិត និងសង្គ្រោះជីវិត។ ជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រនៃពិភពលោក នៅក្នុងពិភពលោកទាំងមូលយើងយល់ថាជីវិតជាអាទិភាពបំផុត សក្ការនៃជីវិតជាអាទិភាពដែលយើងត្រូវការសង្គ្រោះបន្ទាន់។ យើងនឹកឃើញដល់សម្តេចប៉ាប យ៉ូហានប៉ូលទីពីរ ដែលធ្លាប់មានព្រះបន្ទូលអំពីវប្បធម៌នៃសេចក្តីស្លាប់ យើងនឹកឃើញដល់សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូ ប៉ុន្មានដងប៉ុន្មានសាបានមានព្រះបន្ទូលអំពីវប្បធម៌ដែលសុខចិត្តចោលមនុស្សដែលគ្មានប្រយោជ ចោលមនុស្សដែលជិតស្លាប់។ ប៉ុន្តែ ថ្ងៃនេះយើងឃើញហើយកម្លាំងទាំងអស់តាមសង្គមនីមួយៗ ខិតខំយកចិត្តទុកដាក់ដើម្បីឲ្យជីវិតឈ្នះ ដើម្បីសង្គ្រោះជីវិត ដោយសារជីវិតជាអាទិភាព។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងនឹកឃើញពិតមែនជីវិតជាអំណោយទានដែលយើងទទួលពីព្រះជាម្ចាស់ យប់នេះនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធព្រះអង្គបានប្រទានពូជនៃជីវិតអស់កល្បជានិច្ច នៅក្នុងផ្ទៃរបស់ព្រះនាងម៉ារី។ ពិតមែន ពីថ្ងៃដែលព្រះជាម្ចាស់បានបង្កើតពិភពលោករហូតដល់អវសានកាលនៃពិភពលោក យើងបានទទួលអំណោយទានមួយដែលមានសារសំខាន់បំផុត គឺជីវិត។ ព្រះជាម្ចាស់ បានបង្កើតយើងជាមនុស្ស ជាបុរសជាស្ត្រី ឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ ព្រះអង្គបានបង្កើតយើងដើម្បីឲ្យយើងមានជីវិតរស់នៅ។

យប់នេះ ជាពេលវេលាមួយដើម្បីឲ្យពិភពលោកទាំងមូលភ្ញាក់ស្មារតី ដើម្បីឲ្យសាមគ្គីភាព និងភាតរភាពរបស់យើងរីកចម្រើន។ ពិតមែន យើងឃើញព្រំដែននៃប្រទេសនីមួយៗពីមួយថ្ងៃទៅមួយថ្ងៃបានបិទ ប៉ុន្តែតាមកន្លែងនីមួយៗមានសាមគ្គីថ្មីដែលកំពុងរីកចម្រើន ដែលកំពុងផុសចេញពីគ្រប់ទីកន្លែង នៅក្នុងការតយុទ្ធសម្រាប់ជីវិត។ យើងរកឃើញពិភពលោកមួយថ្មី ដែលណែនាំឲ្យយើងយល់ថាពិតមែនពិភពលោករបស់យើងជាភូមិមួយយ៉ាងធំ ដែលមានតែបងប្អូនប

ង្កើត។ ហេតុនេះហើយ គ្រប់សកម្មភាព គ្រប់ស្នាដៃ គ្រប់ការជួយដែលកំពុងមានគ្រប់ទិស ជាសញ្ញាសម្គាល់ដឹងថាយើងមានសមត្ថភាពដើម្បីបង្កើតភាតរភាព ដើម្បីមានសាមគ្គីភាពនៅក្នុងជីវិតរបស់យើង ដើម្បីបង្កើតប្រព័ន្ធថ្មីគឺប្រព័ន្ធនៃសាមគ្គី ប្រព័ន្ធនៃភាតរភាព ដើម្បីប្រឆាំងនឹងកូវីដ១៩សព្វថ្ងៃ និងដើម្បីត្រៀមខ្លួននៅពេលកូវីដ១៩ស្លាប់ហើយ ឲ្យយើងរួមគ្នាកសាងពិភពលោករបស់យើងសាជាថ្មី។ ប្រទេសកំពុងអភិវឌ្ឍន៍សព្វថ្ងៃ ដូចជាអឺរ៉ុប សហរដ្ឋអាមេរិកជាដើម នៅក្នុងទុក្ខលំបាកឥតភ្លេចប្រទេសក្រីក្រ សព្វថ្ងៃគេកំពុងប្រមូលមូនិធិដើម្បីជួយឧបត្ថម្ភទ្រឹបដែលខ្វះលុយក្នុងការប្រឆាំងនឹងកូវីដ១៩។ ទោះបីនៅប្រទេសកម្ពុជាយើង យើងបានទទួលស្វាគមន៍ក្រុមគ្រូពេទ្យនិងអ្នកឯកទេសមកពីប្រទេសចិន ជាមួយសម្ភារៈផ្សេងៗ ដើម្បីជួយប្រទេសកម្ពុជាឲ្យត្រៀមខ្លួន។ យើងឃើញមានប្រជាពលរដ្ឋកម្ពុជាមួយចំនួន បានប្រមូលលុយដើម្បីត្រៀមទុកប្រឆាំងនឹងកូវីដ១៩នៅក្នុងប្រទេសយើង។

សម្រាប់យើងដែលជាគ្រីស្តបរិស័ទ ជាពេលវេលាមួយដើម្បីបង្ហាញថាយើងជាគ្រួសារតែមួយ យើងជាបងប្អូនគ្នាពិតមែន នៅក្នុងភូមិរបស់យើង នៅក្នុងព្រះសហគមន៍របស់យើង។ ដោយនឹកឃើញបងប្អូនចាស់ជរា បងប្អូនដែលខ្វះទីពឹង បងប្អូនដែលបានទទួលជំហានទីពីរត្រៀមខ្លួនទទួលពិធីជ្រមុជទឹក បងប្អូនដែលកំពុងធ្វើដំណើរត្រលប់មកពីប្រទេសថៃ ឲ្យនៅតាមភូមិនីមួយៗដែលមានព្រះសហគមន៍កាតូលិកយើង **តើយើងធ្វើអ្វីខ្លះដើម្បីបង្ហាញថាយើងជាបងប្អូនគ្នានៅក្នុងគ្រួសារតែមួយ?**

យប់នេះ ខ្ញុំសូមអញ្ជើញសមាជិកនៃសម្ពន្ធកាតូលិកដើម្បីអភិវឌ្ឍនិងធម៌មេត្តាករុណាត្រៀមខ្លួនជួបជុំគ្នាដើម្បីសម្រុះសម្រួលសមត្ថភាពដែលយើងមាន សម្រាប់បច្ចុប្បន្ននេះនិងសម្រាប់ពីរបីខែខាងមុខនេះ ដើម្បីជួយឲ្យបងប្អូនតូចតាចដែលបាត់បង់អ្វីៗទាំងអស់ អាចរីកចម្រើនសាជាថ្មីនិងជួយព្យាបាលរបួសយ៉ាងជ្រៅ ដែលមាននៅក្នុងសង្គមកម្ពុជាយើងពេលនេះ។

ឲ្យយើងថែរក្សាការអធិដ្ឋាន ថ្ងៃនេះយើងគោរពព្រះនាងម៉ារីដែលបានរៀបចំដួងចិត្តធ្វើជាអារាមដ៏តូចមួយ ដើម្បីអធិដ្ឋានអចិន្ត្រៃយ៍។ ពិតមែនព្រះជាម្ចាស់ គង់នៅក្នុងដួងចិត្តព្រះនាងម៉ារី ហើយព្រះនាងដឹងថា នៅក្នុងដួងចិត្តព្រះនាងសម្លឹងមើលសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងជីវិតដ៏ពិសេសដែលព្រះជាម្ចាស់ប្រទានឲ្យ។ ហេតុនេះហើយ នៅក្នុងពេលវេលាដែលយើងរងទុក្ខលំបាកទូទាំងពិភពលោក នៅក្នុងពេលវេលាដែលព្រះវិហាររបស់យើងបិទទ្វារ នៅក្នុងពេលវេលាដែលយើងអធិដ្ឋានរួមគ្នាមិនបាន យើងដឹងថានៅក្នុងដួងចិត្តរបស់យើងមានព្រះវិហារដ៏តូចមួយ យើងមានអារាមដ៏តូចមួយ ដែលទទួលស្វាគមន៍វត្តមានរបស់ព្រះជាម្ចាស់ដែលណែនាំឲ្យយើងអធិដ្ឋានអចិន្ត្រៃយ៍។ ហេតុនេះហើយ កុំឲ្យយើងបិទដួងចិត្តរបស់យើង ផ្ទុយទៅវិញឲ្យយើង

បើកដួងចិត្តរបស់យើងឲ្យធំទូលំទូលាយ ដើម្បីទទួលស្វាគមន៍ទុក្ខលំបាកនៃពិភពលោកទាំងមូល និងផ្ញើទៅព្រះជាម្ចាស់។

"**ឱព្រះជាម្ចាស់អើយ! ដែលគង់នៅក្នុងដួងចិត្តរបស់ខ្ញុំ សូមអនុញ្ញាតិឲ្យខ្ញុំចូលនៅក្នុងដួងចិត្តរបស់ខ្ញុំផ្ទាល់ ដើម្បីរកឃើញវត្តមានរបស់ព្រះអង្គ**"។ ខ្ញុំជឿថា មានតែការអធិដ្ឋានដែលណែនាំឲ្យពិភពលោកក្នុងពេលវេលានេះ អាចប្រែប្រួល អាចកែប្រែបាន។ ខ្ញុំសូមអញ្ជើញបងប្អូនគ្រីស្តបរិស័ទទាំងអស់នៅក្នុងប្រទេសកម្ពុជា សូមចូលអភិបូជាជាមួយយើងជារៀងរាល់ថ្ងៃម៉ោង ៦និង ៣០នាទីព្រឹក ដោយថ្វាយខ្លួនជាមួយព្រះជាម្ចាស់ ដោយទទួលព្រះកាយតាមផ្លូវវិញ្ញាណ។ ខ្ញុំសូមអញ្ជើញបងប្អូនទាំងអស់ចូលរួមអធិដ្ឋានផ្គុំជារៀងរាល់ថ្ងៃម៉ោង៧ល្ងាច ជាពិសេសសូមបងប្អូនអធិដ្ឋានជាក្រុមគ្រួសារ ឲ្យយើងយកពេលវេលាដើម្បីអធិដ្ឋានថែមទៀត តាមរយៈបណ្តាញផ្សព្វផ្សាយសង្គមរបស់ព្រះសហគមន៍កាតូលិកកម្ពុជា ផេចហ្វេសបុកផ្លូវការរបស់ការិយាល័យ CSC https://www.facebook.com/catholicphnompenh និង https://www.facebook.com/RVAKhmer និង យូធូប https://www.youtube.com/channel/UCXifCD3q9-cPkVk3gOB9L6Qនិងhttps://www.youtube.com/RVAKhmer ។ ប្រសិនបើ យើងជាគ្រីស្តបរិស័ទតែម្នាក់នៅក្នុងគ្រួសារ យើងសូមអញ្ជើញឪពុកម្តាយបងប្អូនយើងដែលមិនមែនជាគ្រីស្តបរិស័ទ ដើម្បីយកពេលវេលាសមាធិជាមួយគ្នា ដើម្បីនៅស្ងៀមស្ងាត់ជាមួយគ្នា ដើម្បីផ្ញើអ្វីៗទាំងអស់ទៅលើព្រះដែលការពារថែរក្សាយើងជានិច្ច។

បពិត្រព្រះនាងម៉ារី ដែលជាមាតារបស់ព្រះជាម្ចាស់ ព្រះនាងម៉ារីដែលជាមាតារបស់យើង សូមអធិដ្ឋានសម្រាប់យើងខ្ញុំដែលជាអ្នកមានបាបនៅពេលនេះហើយនៅពេលស្លាប់ផង។ អាម៉ែន៕